# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូក្រុមហ៊ុនចិនផ្នែកផលិតស្ងួត្រនាំចេញ



នៅរសៀលថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូក្រុមហ៊ុន **Shangdong Hirun Investment Group Co,Ltd** ដឹកនាំដោយលោក **Wang Wei** ជានាយកក្រុមហ៊ុន ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ ហើយបានចាត់ទុកដំណើរទស្សនៈកិច្ចរបស់ប្រតិភូក្រុមហ៊ុនចិន និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួននឹងសម្រេចបាននូវគម្រោងវិនិយោគរបស់ខ្លួននៅកម្ពុជា ។

លោកនាយកក្រុមហ៊ុន **Wang Wei** បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា គឺចង់បង្កើតរោងចក្រផលិតស្ងួត្រនៅកម្ពុជា សម្រាប់ធ្វើការនាំចេញ ដោយនាំចូលវត្ថុធាតុដើមពីប្រទេសចិន ។ លោក **Wang Wei** បានជម្រាបជូនពីជោគជ័យរបស់ក្រុមហ៊ុន លើការនាំចេញ សូត្រ និងផលិតផលសម្រេចធ្វើពីសូត្រទៅកាន់ទីផ្សារក្រៅប្រទេសប្រមាណ ៣០ ប្រទេស ក្នុងទឹកប្រាក់ជាង៥០០លានដុល្លា ក្នុងមួយឆ្នាំ ជាពិសេស គឺ ទីផ្សារសហគមន៍អឺរ៉ុប និងជប៉ុន ។ ក្នុងនោះផ្ទៃដីសម្រាប់ដាំស្លឹកមន និងចិញ្ចឹមដង្កូវនាង ស្ថិតក្នុងខេត្ត សាងទុង (Shangdong) មានប្រមាណ៧ម៉ឺនហិចតា ។ ប៉ុន្តែបច្ចុប្បន្ន បានកាត់បន្ថយនៅត្រឹម ប្រហែល២ម៉ឺនហិចតាទេ ដោយសារភាពរីកចម្រើនលឿនរបស់សេដ្ឋកិច្ចចិន ធ្វើឱ្យកំលាំងពលកម្មនៅចិនមានតម្លៃកាន់តែខ្ពស់ ។ ដូច្នេះការចាប់អារម្មណ៍វិនិយោគនៅកម្ពុជា ដោយមើលឃើញពីស្ថានភាពអំណោយផលនៅទីនេះ និងស្របនិងគោលនយោបាយរបស់ប្រទេសចិន ដែលជម្រុញលើកទឹកចិត្តឱ្យក្រុមហ៊ុនចិន បន្តបណ្តាក់ទុននៅក្រៅប្រទេសឱ្យបានច្រើន ។



ស្ថិតក្នុងឱកាសនោះ លោក នាយកក្រុមហ៊ុន ក៏ចង់ដឹងពីគោលនយោបាយលើកទឹកចិត្ត នីតិវិធីវិនិយោគ និងការណែនាំមួយចំនួន ពីឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ផងដែរ ។

ជាការឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសាទរចំពោះក្រុមហ៊ុន ដែលដំណាក់កាលដំបូងចង់ជួលរោងចក្រនៅតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ ដែលថ្ងៃអនាគតតំបន់នោះ នឹងក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង ។ ចំពោះគោលនយោបាយលើកទឹកចិត្ត ឯកឧត្តម បានបញ្ជាក់ថា៖ បន្ទាប់ពីក្រុមហ៊ុនទទួលបានលក្ខណៈសម្បត្តិជាអ្នកវិនិយោគតាមច្រក ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC រួចហើយ នឹងទទួលអត្ថប្រយោជន៍មួយចំនួន ដូចជា៖ ការលើកលែងពន្ធលើប្រាក់ចំណេញរយៈពេល០៥ ឆ្នាំ–ការនាំចូលសំភារៈសំណង់បម្រើឱ្យកសាងរោងចក្រក្នុងគម្រោងវិនិយោគរបស់ខ្លួនដោយរួចពន្ធ និងមិនកំរិតការផ្ទេរប្រាក់ចំណេញទៅក្រៅប្រទេសឡើយ។

ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានលើកចំណុចទាក់ទាញមួយទៀតរបស់កម្ពុជា គឺកម្ពុជាទទួលបានភាពអនុគ្រោះពាណិជ្ជកម្ម ពីប្រទេសអភិវឌ្ឍន៍ និងប្រទេសជាដៃគូរជាច្រើនលើពិភពលោក ដែលអនុញ្ញាតឱ្យមុខទំនិញនាំចេញពីកម្ពុជា ប្រមាណ៩៧ % ដោយមិនជាប់ពន្ធ និងមិនជាប់កូតា ។ ទាក់ទងបញ្ហានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានជម្រាបប្រតិភូក្រុមហ៊ុនចិនថា៖ បើក្រុមហ៊ុនចង់នាំចេញ ដោយរួចពន្ធពីកម្ពុជា លុះត្រាក្រុមហ៊ុនប្រើវត្ថុធាតុដើម ដែលផលិតនៅក្នុងស្រុក (Local Content) ដូចជា៖ ការដាំស្លឹកមន និងចិញ្ចឹមដង្កូវនាង ជាដើម ពីព្រោះ ជាលក្ខខ័ណ្ឌតម្រូវតាមកិច្ចព្រមព្រៀងនៃភាពអនុគ្រោះពាណិជ្ជកម្មតាមប្រព័ន្ធ MFN និង GSP ដែលកិច្ចការនេះនឹងជួយដល់ទីផ្សារការងារ និង តម្លៃបន្ថែមក្នុងស្រុក ។

